00640388

E9/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១១

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 01 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់មេធាវីការពារក្តី ស្នើសុំឲ្យមានការផ្លាស់ប្តូរវិធាន ៨០ នៃវិធានផ្ទៃក្នុងដើម្បីបង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញនូវបញ្ជីឥស្សតាងមុនមេធាវីការពារក្តីដែលត្រូវផ្តល់ឲ្យនូវ បញ្ជីឈ្មោះសាក្សីបន្ថែម**

---

ដាក់ដោយ៖

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

00640389



## I. សេចក្តីផ្តើម និង សំណើ

១. វិធាន ៨0 នៃវិធានផ្ទៃក្នុងស្តីពីដំណើរការ និង ភស្តុតាងដែលចែងថា: ក្នុងរយៈពេល ដប់ប្រាំ(១៥) ថ្ងៃក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ, សហព្រះរាជអាជ្ញាត្រូវដាក់បញ្ជីឈ្មោះសាក្សីរបស់ខ្លួនបន្ទាប់មក មេធាវីការពារក្តីនឹងមានពេលវេលាដប់ប្រាំ(១៥)ថ្ងៃបន្ថែមទៀតដើម្បីដាក់បញ្ជីឈ្មោះសាក្សីបន្ថែមទៀត។ វិធាននេះបានចែងបន្ថែមទៀតថា: អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យភាគីដាក់នូវបញ្ជីភស្តុតាងទាំងឡាយ។

២. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញ "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ"[1] ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់នូវបញ្ជីឈ្មោះសាក្សី, វត្ថុតាង និង ឯកសារផ្សេងៗ។

៣. មេធាវីការពារក្តីយល់ឃើញថា វាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់អំពីបញ្ជីនៃឯកសារ និង វត្ថុតាងរបស់សហព្រះរាជអាជ្ញាមុននឹងការដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឈ្មោះសាក្សីបន្ថែមរបស់មេធាវីការពារក្តីនោះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងដើម្បីបង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់ទាំងបញ្ជីឈ្មោះសាក្សី និងបញ្ជីវត្ថុតាងទាំងឡាយនៅមុនពេលបង្គាប់ឲ្យជនជាប់ចោទដាក់នូវបញ្ជីឈ្មោះសាក្សីរបស់ខ្លួន។

## II បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ

៤. វិធាន ៨0 នៃវិធានផ្ទៃក្នុង បានចែងនូវចំណុចដែលពាក់ព័ន្ធថា:

> ១.សហព្រះរាជអាជ្ញាត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនឯកសារថតចម្លង មួយច្បាប់ទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ ។
>
> ២.នៅពេលដែលជនជាប់ចោទ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណីណាមួយ មានបំណងកោះហៅសាក្សីណាម្នាក់ ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែមដល់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សី។ ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុង

[1] អជសដ, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ: E9 ។

សំណុំរឿង និងបញ្ជូនបញ្ជីឈ្មោះថតចម្លងទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ ។

៣.អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យភាគីនៅក្នុងរយៈពេលដែលបានកំណត់នៅមុនពេលសវនាការបឋមដើម្បីដាក់នូវឯកសារដូចខាងក្រោមនេះ

ក) [......]

ខ)បញ្ជីភស្តុតាងដែលភាគីមានបំណងចង់ដាក់នៅក្នុងសំណុំរឿងដោយត្រូវមានការពិពណ៌នាសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា។

[.....] ។

៥. វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងបានចែងថា:

លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៦. វិធាន ២១ នៃវិធានផ្ទៃក្នុងស្តីពីគោលការណ៍ជាសារវ័ន្តចែងថា:

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ

ក-ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ [.........]។

៧. កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) បានចែងនៅក្នុងមាត្រា ១៤(៣)(ង)ថា: មនុស្សគ្រប់រូបមានសិទ្ធិដើម្បីពិនិត្យ ឬ បានពិនិត្យចំពោះសាក្សីដែលប្រឆាំងនឹងខ្លួន។

## III. សេចក្តីសន្និដ្ឋាន

៨. វិធាន ៨៧ នៃវិធានផ្ទៃក្នុង បានចែងថា បន្ទុកដើម្បីបង្ហាញនូវពិរុទ្ធភាពនៃជនជាប់ចោទគឺជាបន្ទុក

របស់សហព្រះរាជអាជ្ញា។មេធាវីការពារក្តីត្រូវតែដឹងអំពីបញ្ហាដែលសហព្រះរាជអាជ្ញាមានបំណងចង់បង្ហាញប្រឆាំងនឹងជនត្រូវចោទនៅសវនាការជម្រះក្តី និងភស្តុតាងដែលសហព្រះរាជអាជ្ញាមានបំណងចង់យកមកសម្អាងដើម្បីបង្ហាញនូវការចោទប្រកាន់របស់ខ្លួន។ ចំណុចនេះតម្រូវឲ្យមេធាវីការពារក្តីត្រូវតែដឹងទាំងសាក្សីដែលគេត្រូវយកមកសម្អាង និងវត្ថុតាងដែលត្រូវយកមកបង្ហាញនៅក្នុងសវនាការជម្រះក្តី។ នៅពេលដែលមេធាវីការពារក្តីបានដឹងអំពីវិសាលភាពនៃបញ្ហាដែលខ្លួនត្រូវប្រឈមតែប៉ុណ្ណោះទើបអាចធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវចំពោះសាក្សីបន្ថែមជាយថាហេតុដែលតម្រូវឲ្យធ្វើសក្ខីកម្មនៅក្នុងដំណើរការនីតិវិធី។

៩. លើសពីនេះទៀតនោះ លក្ខណៈនៃដំណើការនីតិវិធីសួរដេញដោលគ្នានេះតម្រូវឲ្យមេធាវីការពារក្តីមានសិទ្ធិដើម្បីសួរដេញដោលសាក្សីដែលឆ្លើយដាក់បន្ទុកប្រឆាំងនឹងជនជាប់ចោទ។មេធាវីការពារក្តីយល់ឃើញថាគ្មានចម្លើយសាក្សីណាមួយត្រូវយកមកសម្អាងទេ ប្រសិនបើវាមានលក្ខណៈជាដាក់បន្ទុកដោយមិនមានសាក្សីដែលបានផ្តល់ចម្លើយនោះ មកបង្ហាញខ្លួនដោយផ្ទាល់នោះទេ លើកលែងតែភាគីបានព្រមព្រៀងគ្នាប៉ុណ្ណោះ។សិទ្ធិនេះត្រូវបានគាំពារតាមរយៈមាត្រា ១៤(៣)(ង)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែងថា: ជនជាប់ចោទមានសិទ្ធិដើម្បីពិនិត្យមើល ឬបានត្រួតពិនិត្យមើលសាក្សីដែលប្រឆាំងនឹងខ្លួន[2]។ ភាពសមហេតុផលនៃបទបញ្ញត្តិនេះគឺថា គេត្រូវតែផ្តល់ឲ្យមេធាវីការពារក្តីនូវឱកាសស្មើភាពគ្នាដើម្បីជំទាស់តវ៉ានឹងភស្តុតាងដែលប្រឆាំងនឹង ជនជាប់ចោទ ហើយនិងដើម្បីយកមកបង្ហាញភស្តុងរបស់ខ្លួន។ ដូចដែលមានរៀបរាប់ដោយលោក Trechsel:

> សំណួរដែលបានតាំងឡើងដោយមេធាវីការពារក្តីនឹងមិនគ្រាន់តែមានឥទ្ធិពលមកលើការវាយតម្លៃនៃភាពអាចជឿទុកចិត្តបាននៃសាក្សីប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងអាចជួយនាំមកនូវពត៌បន្ថែមទៀតនៃធាតុផ្សេងៗនៃអង្គហេតុដែលអាចមានការពាក់ព័ន្ធសំរាប់សេចក្តីសម្រេចចុងក្រោយរបស់តុលាការដែលវាពាក់ព័ន្ធនឹងការផ្តន្ទាទោសឬការកាត់ទោស[3]។

១០. ដំណើការសាវនាការជំនុំជម្រះក្តីអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដើម្បីដាក់ចម្លើយសាក្សីរបស់បុគ្គលទាំងឡាយណាដែលបានយកចម្លើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដោយមិនចាំបាច់ត្រូវកោះហៅពួកគេជាសាក្សីនៅសវនាការជំនុំជម្រះក្តីនោះទេ។ តាមពិតទៅ អង្គជំនុំជម្រះ

[2] បទបញ្ញត្តិដូចគ្នានេះត្រូវបានចែងនៅក្នុងមាត្រា ៦(៣)(ឃ)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

[3] Stefan Trechsel, សិទ្ធិមនុស្សនៅក្នុងនីតិវិធីព្រហ្មទណ្ឌ(២០០៥), ទំព័រ 292-293 ។

00640392



សាលាដំបូងបានបញ្ជាក់អំពីការអនុវត្តនេះ ហើយដែលលោកប្រធាននៃអង្គជំនុំជម្រះសាលាដំបូងបានអះអាងថា:"ក្រោយពីការអានចម្លើយសាក្សីនីមួយៗបន្ទាប់មកភាគីដែលចូលរួមនៅក្នុងដំណើរការនឹងត្រូវបានផ្តល់ឱកាសដើម្បីធ្វើការកត់សម្គាល់របស់ខ្លួនពាក់ព័ន្ធនឹងការអាននៃចម្លើយនោះនៅក្នុងសវនាការ"[4]។

១១. មេធាវីការពារក្តីមានការព្រួយបារម្ភដើម្បីឲ្យចៀសវាងនូវស្ថានភាពមួយដែលសហព្រះរាជអាជ្ញាស្វះស្វែងដើម្បីលើកមកសម្អាងនៅក្នុងទម្រង់នៃ"វត្ថុតាង",ចម្លើយសាក្សីដែលជាភស្តុតាងដាក់បន្ទុកប្រឆាំងនឹងជនត្រូវចោទដោយមិនបានកោះហៅសាក្សីនោះមកធ្វើសក្ខីកម្ម និងដើម្បីធ្វើការសាកសួរដេញដោល។ មេធាវីការពារក្តីសូមលើកឡើងថានោះវាគឺជាសិទ្ធិជាមូលដ្ឋានដែលត្រូវឲ្យមានវត្តមានសាក្សីណាម្នាក់ដែលផ្តល់ភស្តុតាងដាក់បន្ទុកប្រឆាំងនឹងជនត្រូវចោទនៅក្នុងតុលាការ ដើម្បីឲ្យភស្តុតាងនោះអាចត្រូវបានគេធ្វើការវាយតម្លៃ។ ការអនុវត្តន៍នាពេលបច្ចុប្បន្ននេះនៅអវតកបានអនុញ្ញាតឲ្យបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញាក្នុងការមិនដាក់បញ្ចូលសាក្សីដែលបានយកចម្លើយដោយសហចៅក្រមស៊ើបអង្កេត និងដែលមានភស្តុតាងដាក់បន្ទុកដ៏មានសក្តានុពលប្រឆាំងនឹងជនត្រូវចោទ។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារក្តីនឹងមិនត្រូវបន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះសាក្សីបន្ថែមរបស់ខ្លួននោះឡើយ។

១២. នៅក្នុងប្រព័ន្ធទូទៅនៃឯអវតក ប្រសិនបើសហព្រះរាជអាជ្ញាបានសម្រេចក្រោយមកទៀតដើម្បីបញ្ចូលនូវចម្លើយសាក្សីដែលធ្វើឲ្យអន្តរាយជាសក្តានុពលនៃ កសចស ធ្វើជាវត្ថុតាងនោះ ដូច្នេះការបង្ហាញភស្តុតាងដោយមិនបានកោះហៅសាក្សីនោះទេ ពិតជាធ្វើឲ្យមេធាវីការពារក្តីទទួលរងនូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរ។ វាមិនអាចទៅរួចទេចំពោះការជំទាស់តវ៉ាដែលមានន័យត្រឹមត្រូវទៅនឹងខ្លឹមសារនៃចម្លើយសាក្សីនៅពេលដែលសាក្សីនោះអវត្តមាននោះ។

១៣. លើសពីនេះទៀតនោះ ចំណុចនេះបានរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការត្រួតពិនិត្យឬបានពិនិត្យវាយតម្លៃលើសាក្សីដែលប្រឆាំងនឹងខ្លួនដូចដែលមានចែងនៅក្នុងមាត្រា ១៤(៣)(ង)នៃកតិការសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

---

[4] អជសដ, សំណុំរឿងលេខ: ០០១, ប្រតិចារិក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៩, ទំព័រ ៧៧ ។

## IV សំណូមពរ

១៤. ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅខាងលើ មេធាវីការពារក្តីសូមស្នើ អង្គជំនុំជម្រះសាលាដំបូងដើម្បីបង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញទាំងបញ្ជីឈ្មោះសាក្សី និង វត្ថុតាងឲ្យបានមុនពេលតម្រូវឲ្យជនត្រូវចោទដាក់បង្ហាញបញ្ជីឈ្មោះសាក្សីបន្ថែម និងបញ្ជីវត្ថុតាង បន្ថែមរបស់ខ្លួននោះ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |